# បេឡាជាតិរបបសន្តិសុខសង្គម

# National Social Security Fund

ព្រឹត្តិបត្រព័ត៌មាន

ប.ស.ស ឆ្នាំទី០៨
លេខ២៤ ឆ្នាំ ២០១៨



**ទំនាក់ទំនងបន្ទាន់**
**២៤ម៉ោង/៧ថ្ងៃ**
**១២៨៦**

អ្នកមានជួយអ្នកក្រ
អ្នកមានសុខភាពល្អ
ជួយអ្នកឈឺ

**ធានាសន្តិសុខប្រាក់ចំណូល**

**រួមចំណែកកាត់បន្ថយភាពក្រីក្រ**

**លើកកម្ពស់ស្ថិរភាពសង្គម**





# មាតិកាព្រឹត្តិបត្រព័ត៌មាន ប.ស.ស


| ល.រ | ខ្លឹមសារអត្ថបទ | ទំព័រ |
|---|---|---|
| ០១ | សសរស្តម្ភពីរក្នុងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ក្នុងនោះប្រពន្ធ័សន្តិសុខសង្គមបានរួមចំណែកយ៉ាងសំខាន់.... | ០១ |
| ០២ | ប.ស.ស ផ្តល់ប័ណ្ណសមាជិករបស់ខ្លួន ចំនួន ២ ៤៦៩ប័ណ្ណ ដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងវប្បធម៌..... | ០៤ |
| ០៣ | បេឡាជាតិរបបសន្តិសុខសង្គម ផ្តល់ប័ណ្ណសមាជិករបស់ខ្លួន ចំនួន ៨៥២ប័ណ្ណ ដល់មន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា........ | ០៦ |
| ០៤ | ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងមុខងារសាធារណៈទទួលបាន ប័ណ្ណសមាជិក ប.ស.ស................ | ០៨ |
| ០៥ | មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងធម្មការ និងសាសនា ទទួលបានប័ណ្ណសមាជិក ប.ស.ស ចំនួន ១៦២១ប័ណ្ណ.... | ១១ |
| ០៦ | ប.ស.ស ផ្តល់ការពិនិត្យ និងព្យាបាលជំងឺមហារីកដល់សមាជិក ប.ស.ស ទាំងស្រុង ខណៈដែលសេវានេះបណ្តាប្រទេស........ | ១៤ |
| ០៧ | បេឡាជាតិរបបសន្តិសុខសង្គម ផ្តល់ប័ណ្ណសមាជិក ប.ស.ស ចំនួនជាង ៦ពាន់ប័ណ្ណ លើកទី១ សម្រាប់មន្ត្រីរាជការ.......... | ១៧ |
| ០៨ | សិក្ខាសាលា ស្តីពីការពង្រីកវិសាលភាពគាំពារសង្គមដល់កម្មករនិយោជិតលើវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា | ១៩ |
| ០៩ | គិតត្រឹមឆមាសទី១ ឆ្នាំ២០១៨ មានមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ទៅទទួលសេវាថែទាំសុខភាព........ | ២១ |
| ១០ | ប័ណ្ណសមាជិក ប.ស.ស ចំនួន ៧៩៤ ប័ណ្ណបាន ផ្តល់ជូនមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៅក្រសួងទំនាក់ទំនងរដ្ឋសភា | ២២ |
| ១១ | ប.ស.ស ប្រគល់ប័ណ្ណសមាជិករបស់ខ្លួន ចំនួន ៨១០ប័ណ្ណ ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា......... | ២៤ |
| ១២ | បេឡាជាតិរបបសន្តិសុខសង្គម បានផ្តល់ប័ណ្ណសមាជិករបស់ខ្លួន ចំនួន ១៦២១ប័ណ្ណ ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ............ | ២៦ |
| ១៣ | ចំនួនអ្នកមានប័ណ្ណបើកបរដឹកម្ករបានកើនឡើងដល់ ៣ ៥៩១ នាក់ ស្មើនឹង ៨២% ក្នុងចំណោមអ្នកបើកបរសរុប ៤ ៣៦៩នាក់ | ២៩ |








| | | |
|---|---|---|
| ១៤ | បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)កម្ពុជា ទទួលបានពានរង្វាន់ ស្តីពីការផ្តល់សេវាល្អសម្រាប់របបថែទាំសុខភាព.... | ៣១ |
| ១៥ | វគ្គបណ្តុះបណ្តាលស្តីពី នីតិវិធីចុះបញ្ជិកា នីតិវិធីទាមទារតាវកាលិក និងការទទួលបានអត្ថប្រយោជន៍ ប.ស.ស........... | ៣២ |
| ១៦ | ឯកឧត្តម ហ៊ុន ម៉ានី ចុះសួរសុខទុក្ខបងប្អូនកម្មករ ជួបគ្រោះថ្នាក់ចរាចរណ៍ចំនួន ២២នាក់ នៅមន្ទីរពេទ្យព្រះកុសុមៈ | ៣៤ |
| ១៧ | កិច្ចប្រជុំពិគ្រោះយោបល់ជាមួយមូលដ្ឋានសុខាភិបាលថ្នាក់ជាតិ អំពីការកំណត់តម្លៃឱសថក្រៅពីបញ្ជីឱសថសារវន្ត | ៣៦ |
| ១៨ | អ្នកព្រះភិរម្យ ភាសាអ៊ូ ហៅង៉ុង | ៣៧ |
| ១៩ | ខ្វះជាតិស្ករក្នុងឈាម គួរធ្វើដូចម្តេចទៅ? | ៣៨ |









# រចនាសម្ព័ន្ធព្រឹត្តិបត្រ

## ឯកឧត្តម អ៊ុក សមវិទ្យា
## នាយក ប.ស.ស

| | |
|---|---|
| ចាងហ្វាង | ឯកឧត្តម ហេង សុផាន់ណារិទ្ធ |
| និពន្ធនាយក | លោក យ៉ាម យុទ្ធា |
| និពន្ធនាយករង | លោក យុន វិចិត្រ |
| | លោក នៅ សុមនា |
| | លោក វ៉ាន់ ចាន់ថន |
| លេខានិពន្ធ | កញ្ញា រ៉ាត់ ម៉ាលីកា |
| | លោក នាង ជូ |
| | លោក យន គន្ធា |
| | លោក អ៊ុង លាងឆុង |
| | លោក លីម តក់ |
| ផ្នែកភារីកុំព្យូទ័រ | លោក ប៊ុត ស៊ីម |
| | លោក យង់ សុខន |
| | លោក អ៊ុង ស៊ីវឿ |

# សសរស្តម្ភពីរក្នុងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ក្នុងនោះប្រពន្ធ័សន្តិសុខសង្គមបានរួមចំណែកយ៉ាងសំខាន់ក្នុងការរក្សា នូវសុខុមាលភាពរបស់បងប្អូនកម្មករនិយោជិត



**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយក ប.ស.ស បានថ្លែងថា៖ សសរស្តម្ភពីរក្នុងក្របខណ្ឌ គោលនយោបាយជាតិគាំពារសង្គម ក្នុងនោះប្រព័ន្ធសន្តិសុខសង្គមបានរួមចំណែកយ៉ាងសំខាន់ ក្នុងការរក្សានូវសុខុមាលភាព របស់កម្មករនិយោជិត។

ការលើកឡើងពីសំណាក់ ឯកឧត្តមប្រតិភូ គឺធ្វើឡើងក្នុងពិធីប្រគល់-ទទួលប័ណ្ណសមាជិក ប.ស.ស ចំនួន ២ ៦៦៨ ប័ណ្ណនិងផ្សព្វផ្សាយអំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គមជូនដល់ ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួង ផែនការ នៅថ្ងៃព្រហស្បតិ៍ ១៤រោច ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៦ ខែធ្នូ ឆ្នាំ ២០១៨ ។





**ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាលបានលើកឡើងទៀតថា៖ រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវក្របខណ្ឌគោលនយោបាយជាតិ គាំពារសង្គម ឆ្នាំ២០១៦-២០២៥ ដើម្បីសម្រេចបាន "កំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងបរិយាប័ន្ន" ។ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម គឺមានលក្ខណៈទូលំទូលាយ ដោយផ្តោតលើសសរស្តម្ភពីរគឺ ប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម។

១. ប្រព័ន្ធជំនួយសង្គម រួមមាន៖

– ការឆ្លើយតបទៅនឹងគ្រោះអាសន្ន
– ការអភិវឌ្ឍមូលធនមនុស្ស
– ការបណ្តុះបណ្តាលវិជ្ជាជីវៈ
– សុខុមាលភាពរបស់ប្រជាជនងាយរងគ្រោះ

២. ប្រព័ន្ធសន្តិសុខសង្គម រួមមាន៖

– ផ្នែកសោធន
– ការថែទាំសុខភាព
– ហានិភ័យការងារ
– និកម្មភាព
– ពិការភាព

សសរស្តម្ភពីរ ក្នុងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម មិនត្រឹមតែរួមចំណែកជាឧបករណ៍បម្រើដល់ការកាត់បន្ថយ និងទប់ស្កាត់ភាពក្រីក្រ ភាពងាយរងគ្រោះ វិសមភាពសង្គម រួមចំណែកដល់ការអភិវឌ្ឍ និងជម្រុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព តែក្នុងនោះ ក៏បានបង្ហាញពីការរួមចំណែកយ៉ាងសំខាន់ក្នុងការរក្សាសុខុមាលភាពកម្មករនិយោជិតផងដែរ ។







**ឯកឧត្តម ប្រតិភូ** បានថ្លែងរំលឹកបន្តទៀតថា៖ តាមរយៈការអនុវត្តរបបសន្តិសុខសង្គម សម្រាប់វិស័យឯកជនប្រកបដោយជោគជ័យគួរជា ទីមោទនៈកន្លងមក ប.ស.ស ត្រូវបានរាជរដ្ឋាភិបាលផ្តល់ទំនុកចិត្ត និងបានប្រគល់ភារកិច្ចបន្ថែមជាប្រតិបត្តិករតែមួយគត់ក្នុងការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ សម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាព សម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន មានបញ្ញត្តិនៅក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ។





នៅដើមឆ្នាំ២០១៨ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន បានដាក់ឱ្យដំណើរការ នូវសេវាតាវកាលិករួមមាន៖

– សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ
– សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះចំពោះករណីសង្គ្រោះបន្ទាន់
– សេវាបញ្ជូនសព និង សេវាបង្ការសុខភាព ។

គិតរហូតមកដល់ពេលនេះ មានមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ទៅទទួលសេវាសុខភាពបានចំនួន ២២០០១ ដង-នាក់ (ករណី)។ ទាក់ទងទៅនឹងប្រព័ន្ធសន្តិសុខសង្គម នៃគោលនយោបាយជាតិគាំពារសង្គមរហូតមកដល់ពេលនេះ ប.ស.ស បានផ្តល់តាវកាលិកផ្នែក ហានិភ័យការងារដល់ជនរងគ្រោះជាកម្មករនិយោជិតចំនួន ២១៤ ៣៧០ នាក់ ក្នុងចំណោមកម្មករនិយោជិតជាសមាជិកចំនួន ១ ៤៨៧ ៤៩១នាក់ នៃរោងចក្រ សហគ្រាសចំនួន១២ ៦៨៨សហគ្រាស។ ដោយឡែក សម្រាប់ផ្នែកថែទាំសុខភាព ប.ស.ស បានផ្តល់សេវាដល់ កម្មករនិយោជិតចំនួន ១ ៨៥២ ០៤៦ ដង-នាក់ (ករណី) ក្នុងចំណោមកម្មករនិយោជិតប្រមាណជាង ១ ៥៩២ ៥៥៧នាក់ នៃរោងចក្រ សហគ្រាសចំនួនជាង ៨ ៥០៨ សហគ្រាស។



ប.ស.ស ក៏ត្រូវទទួលបន្ទុកលើការងារចុះបញ្ជីកម្មករនិយោជិតក្រៅប្រព័ន្ធ ដើម្បីទទួលបានសេវាមូលនិធិសមធម៌-សុខាភិបាល ដែលមកដល់បច្ចុប្បន្នបានចុះបញ្ជីសហគ្រាសចំនួន ២៣ ១៨៣ សហគ្រាស និងកម្មករនិយោជិតចំនួន ១៣៧ ៨៤៥នាក់ និងទទួលរៀបចំ បើកប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលកម្ពុជាដល់កម្មករនិយោជិតជាស្ត្រីទាំងក្នុង និងក្រៅប្រព័ន្ធ ក្រោយសម្រាលកូន ដែលគិតត្រឹមថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ ២០១៨ មានកម្មករនិយោជិតជាស្ត្រីសម្រាលកូនសរុបចំនួន ៥៩ ១៧១នាក់ កូនចំនួន ៥៩ ៦១៣នាក់ និងចំណាយទឹកប្រាក់អស់ចំនួន ២៣ ៨៤៥ ២០០ ០០០រៀល ។





# ប.ស.ស ផ្តល់ប័ណ្ណសមាជិករបស់ខ្លួន ចំនួន ២៤៦៩ប័ណ្ណ ដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រៀបចំពិធីប្រគល់-ទទួលប័ណ្ណ សមាជិក ប.ស.ស ចំនួន ២៤៦៩ប័ណ្ណ ជូនដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីឱ្យពួកគាត់ទទួលបានសេវាថែទាំសុខភាពនៅមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស។





ឯកឧត្តម សំរាំង កំសាន្ត រដ្ឋលេខាធិការ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ពិធីនេះប្រព្រឹត្តទៅនៅថ្ងៃពុធ ៥កើត ខែមិគសិរ ឆ្នាំចសំរឹទ្ធិស័កព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ ស្ថិតនៅក្នុងសាលប្រជុំ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ ពិធីផ្តល់ប័ណ្ណខាងលើនេះ ប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម សំរាំង កំសាន្ត** រដ្ឋលេខាធិការ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈព្រមទាំងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីតំណាងអង្គភាពស្ថាប័ន ក្រោមឱវាទ សរុបប្រមាណជាង ១០០នាក់ ។

តាមរយៈការអនុវត្តរបបសន្តិសុខសង្គមសម្រាប់វិស័យឯកជនប្រកបដោយជោគជ័យគួរជាទីមោទនៈកន្លងមក ប.ស.ស ត្រូវបានរាជរដ្ឋាភិបាលផ្តល់ទំនុកចិត្ត និងបានប្រគល់ភារកិច្ចបន្ថែមជាប្រតិបត្តិករតែមួយគត់ក្នុងការគ្រប់គ្រងនិងចាត់ចែងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន មានបញ្ញត្តិនៅក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ។នេះសបញ្ជាក់អំពីការយកចិត្តទុកដាក់បំផុត ពីសំណាក់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាចំពោះសុខុមាលភាព និងជីវភាពរស់នៅរបស់មន្ត្រីសាធារណៈ ទាំងអស់ដែលជានិយោជិតរបស់រដ្ឋ។នៅដើមឆ្នាំ២០១៨ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន បានដាក់ឱ្យដំណើការ នូវកញ្ចប់តាវកាលិករួមមាន៖

– សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ
– សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះ
  ចំពោះករណីសង្គ្រោះបន្ទាន់ និង សេវាបញ្ជូនសព
– សេវាបង្ការសុខភាព ។

**ឯកឧត្តម** ប្រតិភូ បានថ្លែងបញ្ជាក់បន្ថែមទៀតថា រហូតមកដល់ពេលនេះ ប.ស.ស បានចុះបញ្ជីមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន សរុបចំនួន ៣១៤ ០៧៦នាក់ (មន្ត្រីរាជការចំនួន២០៤ ០៨៤នាក់ អតីតមន្ត្រីរាជការចំនួន ៥៥ ២២២នាក់ អតីតយុទ្ធជនចំនួន ៥៤ ៧៧០នាក់) និងមានមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនទៅទទួលសេវាថែទាំសុខភាពបានចំនួន ២២ ០០១ ដង-នាក់។

**ឯកឧត្តម** ប្រតិភូ បានបន្តទៀតថា ប.ស.ស នឹងបន្តពង្រឹងនិងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងបន្តជម្រុញ ការអនុវត្តផ្នែកថែទាំសុខភាពទាំងសម្រាប់កម្មករនិយោជិត និងមន្ត្រីសាធារណៈ និងខិតខំរៀបចំដាក់ឱ្យដំណើរការផ្នែកប្រាក់សោធនសម្រាប់ កម្មករនិយោជិតនិងផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈនៅឆ្នាំ២០១៩៕







# បេឡាជាតិរបបសន្តិសុខសង្គម ផ្តល់ប័ណ្ណសមាជិករបស់ខ្លួន ចំនួន ៨៥២ប័ណ្ណ ដល់មន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងនិវត្តជន នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានរៀបចំពិធីប្រគល់-ទទួល ប័ណ្ណសមាជិក ប.ស.ស ចំនួន ៨៥២ប័ណ្ណជូនដល់មន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងនិវត្តជន នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីទទួលបានសេវាថែទាំសុខភាពនៅមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ដែលប្រព្រឹត្តទៅនៅថ្ងៃអង្គារ ១៣រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ត្រូវនឹងថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្ថិតនៅក្នុងសាលប្រជុំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

ពិធីផ្តល់ប័ណ្ណខាងលើនេះ ប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម អ៊ុំ សារិទ្ធ** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈព្រមទាំងមានការអញ្ជើញចូលរួមពីតំណាង ស្ថាប័ន និងអង្គភាព ពាក់ព័ន្ធនានា សរុបប្រមាណជា ១៤៨នាក់។



ឯកឧត្តម អ៊ុំ សារិទ្ធ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

ក្នុងឱកាសនោះដែរ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស បានថ្លែងបញ្ជាក់ថា បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) គឺជាគ្រឹះស្ថានសាធារណៈរដ្ឋបាលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនិងស្ថិតនៅក្រោមអាណាព្យាបាល ហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៧ និងបានចាប់ផ្តើមដំណើរការចុងឆ្នាំ២០០៨។

តាមរយៈការអនុវត្តរបបសន្តិសុខសង្គមសម្រាប់វិស័យឯកជនប្រកបដោយជោគជ័យគួរជាទីមោទនៈកន្លងមក ប.ស.ស ត្រូវបានរាជរដ្ឋាភិបាលផ្តល់ទំនុកចិត្ត និងបានប្រគល់ភារកិច្ចបន្ថែមជាប្រតិបត្តិករតែមួយគត់ក្នុងការគ្រប់គ្រងនិងចាត់ចែងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់ មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន មានបញ្ញត្តិនៅក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ។

នេះសបញ្ជាក់អំពីការយកចិត្តទុកដាក់បំផុតពីសំណាក់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃនិងប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាចំពោះសុខុមាលភាព និងជីវភាពរស់នៅរបស់មន្ត្រីសាធារណៈទាំងអស់ដែលជានិយោជិតរបស់រដ្ឋ។

នៅដើមឆ្នាំ ២០១៨ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន បានដាក់ឱ្យដំណើការ នូវសេវាតាវកាលិករួមមាន៖

- សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ
- សេវាបញ្ជូនអ្នកជំងឺ ឬ ជនរងគ្រោះចំពោះករណីសង្គ្រោះបន្ទាន់
- សេវាបញ្ជូនសព និង សេវាបង្ការសុខភាព ។

គិតរហូតមកដល់ពេលនេះ មានមន្ត្រីសាធារណៈអតីតមន្ត្រីរាជការ និង អតីតយុទ្ធជន ទៅទទួលសេវាសុខភាពបានចំនួន១៨ ៣២៥ ដង-នាក់ (ករណី)។













**ឯកឧត្តមប្រតិភូ** បានថ្លែងបញ្ជាក់បន្ថែមថាគិតមកដល់បច្ចុប្បន្ននេះ ប.ស.ស បានផ្តល់តាវកាលិកផ្នែកហានិភ័យការងារ ដល់ជនរងគ្រោះជាកម្មករនិយោជិត សរុបចំនួន ២១៣ ០២៥នាក់ ក្នុងចំណោមកម្មករនិយោជិតជាសមាជិកចំនួន ១ ៤៨០ ៩៣២ នាក់ នៃរោងចក្រសហគ្រាស ចំនួន ១២ ៥៨៨ សហគ្រាស។ ដោយឡែកសម្រាប់ផ្នែកថែទាំសុខភាព បានផ្តល់សេវាដល់កម្មករនិយោជិតប្រមាណជាង ១ ៥៩០ ៥៨២ ដង-នាក់ (ករណី) ក្នុងចំណោមកម្មករនិយោជិតប្រមាណជាង ១ ៨០៩ ០៥០នាក់ នៃរោងចក្រ សហគ្រាសចំនួនជាង ៨ ២៦៩ ។ ក្រៅពីការងារខាងលើ ប.ស.ស ក៏ត្រូវទទួលបន្ទុកលើការងារ ចុះបញ្ជីកម្មករនិយោជិតក្រៅប្រព័ន្ធដើម្បីទទួលបានសេវាមូលនិធិសមធម៌សុខាភិបាល ដែលមកដល់ពេលនេះ បានចុះបញ្ជីសហគ្រាសចំនួន ២៣ ២៩៣ សហគ្រាស និងកម្មករនិយោជិតចំនួន ១៣៨ ០១៤នាក់ និង ទទួលរៀបចំបើកប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាល ដល់កម្មករនិយោជិតជាស្ត្រីទាំងក្នុង និងក្រៅប្រព័ន្ធ ក្រោយសម្រាលកូនដែលគិតត្រឹមថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨ មានកម្មករនិយោជិតជាស្ត្រីសម្រាលកូនចំនួន ៥២ ៣៩១នាក់ កូនចំនួន ៥២ ៧៧៧ នាក់ ៕



# ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងមុខងារសាធារណៈទទួលបាន ប័ណ្ណសមាជិក ប.ស.ស ចំនួន ៨៤៣ប័ណ្ណ ពីបេឡាជាតិរបបសន្តិសុខសង្គម

បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីថ្ងៃចន្ទ ៥កើត ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ នេះ បានសហការជាមួយ ក្រសួងមុខងារសាធារណៈ រៀបចំពិធីចែកប័ណ្ណសមាជិក ប.ស.ស ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងមុខងារសាធារណៈ ចំនួន ៨៤៣ប័ណ្ណ ដើម្បីឱ្យពួកគាត់ទទួលបានសេវាថែទាំសុខភាព នៅមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ។



ឯកឧត្តមកិត្តិបណ្ឌិត ពេជ្រ ប៊ុនធិន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ



ពិធីចែកប័ណ្ណខាងលើស្ថិតក្រោមអធិបតីភាព **ឯកឧត្តមកិត្តិបណ្ឌិត ពេជ្រ ប៊ុនធិន** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងមានការអញ្ជើញចូលរួមពីតំណាង ស្ថាប័ន និងអង្គភាព ពាក់ព័ន្ធនានា សរុបប្រមាណជា ១៥០នាក់ នៅសាលប្រជុំ នៃក្រសួងមុខងារសាធារណៈ រាជធានីភ្នំពេញ ។

ផ្ដើមចេញពីនេះ **ឯកឧត្តមកិត្តិបណ្ឌិត ពេជ្រ ប៊ុនធិន** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ បានថ្លែងថា នេះជាលើកដំបូងហើយ ដែលបេឡាជាតិរបបសន្តិសុខសង្គម បានផ្ដល់ប័ណ្ណសមាជិក ប.ស.ស សម្រាប់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងមុខងារសាធារណៈ ដែលមានមន្ត្រីរាជការ សរុបចំនួន ២ ០៩១នាក់ ក្នុងនោះមន្ត្រីរាជការស៊ីវិលមានចំនួន ៩៤២នាក់ មន្ត្រីជាប់កិច្ចសន្យាចំនួន ២០៨នាក់ មន្ត្រីរាជការនៅទីស្តីការក្រសួងសរុបចំនួន ៥៤៣នាក់ និងមន្ត្រីរាជការនៅតាមមន្ទីរមុខងារសាធារណៈ រាជធានី ខេត្ត ចំនួន ៣៩៨នាក់ ដែលនឹងត្រូវទទួលបានប័ណ្ណសមាជិក ប.ស.ស សម្រាប់ប្រើប្រាស់ក្នុងការទៅទទួលសេវាពិនិត្យ និងព្យាបាលជំងឺនៅតាមមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស។



ក្នុងឱកាសនោះដែរ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស បានថ្លែងថា តាមរយៈការអនុវត្តរបបសន្តិសុខសង្គម សម្រាប់វិស័យឯកជន ប្រកបដោយជោគជ័យគួរជាទីមោទនៈ កន្លងមក ប.ស.ស ត្រូវបានរាជរដ្ឋាភិបាលផ្តល់ទំនុកចិត្តនិងបានប្រគល់ភារកិច្ចបន្ថែមជាប្រតិបត្តិករតែមួយគត់ក្នុងការគ្រប់គ្រង និង ចាត់ចែងរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ សម្រាប់ មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន មានបញ្ញត្តិនៅក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ។



នៅដើមឆ្នាំ២០១៨ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន បានដាក់ឱ្យដំណើការ នូវសេវាតាវកាលិករួមមាន៖

- សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ
- សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះចំពោះករណីសង្គ្រោះបន្ទាន់
- សេវាបញ្ជូនសព និង សេវាបង្ការសុខភាព ។

គិតរហូតមកដល់ពេលនេះ មានមន្ត្រីសាធារណៈអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ទៅទទួលសេវាសុខភាពបានចំនួន ១៨ ៣២៥ ដង-នាក់ (ករណី)។

នេះសបញ្ជាក់ពី ការយកចិត្តទុកដាក់បំផុតពីសំណាក់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះសុខុមាលភាព និងជីវភាពរស់នៅរបស់មន្ត្រីសាធារណៈទាំងអស់ដែលជានិយោជិតរបស់រដ្ឋ។



**ឯកឧត្តមប្រតិភូ** បានថ្លែងបញ្ជាក់បន្ថែមថា ប.ស.ស នឹងបន្តពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ នឹងបន្តជម្រុញការអនុវត្តផ្នែកថែទាំសុខភាពទាំងសម្រាប់កម្មករនិយោជិត និងមន្ត្រីសាធារណៈ និងខិតខំរៀបចំដាក់ឱ្យដំណើរការ ផ្នែកប្រាក់សោធនសម្រាប់កម្មករនិយោជិតនិងផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ នៅឆ្នាំ២០១៩ ។

**ឯកឧត្តមប្រតិភូ** បានថ្លែងបន្តទៀតថា គិតមកដល់បច្ចុប្បន្ននេះ ប.ស.ស បានផ្តល់តាវកាលិកផ្នែកហានិភ័យការងារដល់ជនរងគ្រោះជាកម្មករនិយោជិត សរុបចំនួន ២១៣ ០២៥នាក់ ក្នុងចំណោមកម្មករនិយោជិតជាសមាជិក ចំនួន ១ ៤៨០ ៩៣២ នាក់ នៃរោងចក្រ សហគ្រាស ចំនួន ១២ ៥៨៨សហគ្រាស។





ដោយឡែកសម្រាប់ផ្នែកថែទាំសុខភាព បានផ្តល់សេវាដល់កម្មករនិយោជិតប្រមាណជាង ១ ៥៩០ ៥៨២ ដង-នាក់ (ករណី) ក្នុងចំណោមកម្មករនិយោជិតប្រមាណជាង ១ ៨០៩ ០៥០នាក់ នៃរោងចក្រ សហគ្រាស ចំនួនជាង ៨ ២៦៩ ។ ក្រៅពីការងារខាងលើ ប.ស.ស ក៏ត្រូវទទួលបន្ទុកលើការងារចុះបញ្ជីកម្មករនិយោជិតក្រៅប្រព័ន្ធដើម្បីទទួលបានសេវាមូលនិធិសមធម៌សុខាភិបាល ដែលមកដល់ពេលនេះ បានចុះបញ្ជីសហគ្រាសចំនួន ២៣ ២៩៣សហគ្រាស និងកម្មករនិយោជិតចំនួន ១៣៨ ០១៤នាក់ និងទទួលរៀបចំបើកប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលដល់កម្មករនិយោជិតជាស្ត្រីទាំងក្នុងនិងក្រៅប្រព័ន្ធ ក្រោយសម្រាលកូន ដែលគិតត្រឹមថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៨ មានកម្មករនិយោជិត ជាស្ត្រីសម្រាលកូនចំនួន ៥៣ ៧២៧នាក់ កូនចំនួន ៥៤ ១២០នាក់៕





# មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងធម្មការ និងសាសនា ទទួលបានប័ណ្ណសមាជិក ប.ស.ស ចំនួន ១៦២១ប័ណ្ណ ពីបេឡាជាតិរបបសន្តិសុខសង្គម

បេឡាជាតិរបបសន្តិសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយក្រសួងធម្មការ និងសាសនា បានរៀបចំពិធីប្រគល់ ប័ណ្ណសមាជិក ប.ស.ស និងផ្សព្វផ្សាយអំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម ជូនដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងធម្មការ និងសាសនា ដែលប្រព្រឹត្តទៅនៅថ្ងៃសុក្រ ៩កើត ខែកត្តិក ឆ្នាំចសំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅក្នុងទីស្តីការក្រសួងផ្ទាល់។









ពិធីនេះប្រព្រឹត្តិទៅក្រោមអធិបតីភាព **ឯកឧត្តម នរៈ រតនវឌ្ឍនោ** រដ្ឋលេខាធិការ និងជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមហ៊ឹម ឆែម** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គមព្រមទាំងមានការអញ្ជើញចូលរួមពី ថ្នាក់ដឹកនាំ និងមន្ត្រីតំណាង ស្ថាប័នអង្គភាព ក្រោមឱវាទ សរុបប្រមាណជា ១២០នាក់។

**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម បានថ្លែងថា គោលបំណងនៃពិធីនេះ គឺដើម្បីផ្តល់ប័ណ្ណសមាជិក ប.ស.ស ជូនដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងធម្មការ និងសាសនា សម្រាប់ទៅទទួលសេវា របបសន្តិសុខសង្គម នៅតាមមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស និងផ្សព្វផ្សាយអំពីគោលនយោបាយ របបសន្តិសុខសង្គម សម្រាប់មន្ត្រីរាជការ និងកម្មករនិយោជិតផងដែរ។

**ឯកឧត្តមប្រតិភូ** បានថ្លែងបន្តទៀតថា៖ ចាប់តាំងពីឆ្នាំ២០០៨ រហូតមកដល់បច្ចុប្បន្ន ប.ស.ស បានពង្រីកវិសាលភាពរបស់ខ្លួនគ្របដណ្តប់ ទូទាំងប្រទេសដោយមានមន្ត្រីរាជការ និងបុគ្គលិកដែលកំពុងបម្រើការងារសរុប ចំនួន ១ ៤៧៣នាក់ ក្នុងនោះមានមន្ត្រីរាជការចំនួន ២២៣នាក់ និងបុគ្គលិកជាប់កិច្ចសន្យាចំនួន ១ ២៥០នាក់។

**ឯកឧត្តមប្រតិភូ** បានបញ្ជាក់បន្ថែមថា៖ អនុលោមតាមប្រកាសអន្តរក្រសួងលេខ ២៩១ ក.ប/ប្រ.ក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីកិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាល រវាងបេឡាជាតិរបបសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាលសម្រាប់ ផ្នែកថែទាំសុខភាព ប.ស.ស បានចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលចាប់ពីថ្នាក់មណ្ឌលសុខភាព រហូតដល់ថ្នាក់ជាតិចំនួន ១៣៣៥ មូលដ្ឋានសុខាភិបាល នៅក្នុងនោះមានមន្ទីរពេទ្យរដ្ឋចំនួន ១ ២៩២ និងមន្ទីរពេទ្យឯកជនចំនួន ៤៣។











**ឯកឧត្តម ប្រតិភូ** បន្តថា៖ រហូតមកដល់បច្ចុប្បន្ន ប.ស.ស បានផ្តល់តាវកាលិកផ្នែកហានិភ័យការងារដល់ជនរងគ្រោះជាកម្មករនិយោជិត ចំនួន ២១៤ ៣៧០នាក់ ក្នុងចំណោមកម្មករនិយោជិតជាសមាជិកចំនួន ១ ៤៨៧ ៤៩១នាក់ នៃរោងចក្រសហគ្រាសចំនួន ១២៦៨៨ សហគ្រាស។ ដោយឡែកសម្រាប់ផ្នែកថែទាំសុខភាព បានផ្តល់សេវាដល់កម្មករនិយោជិត ចំនួន ១ ៨៥២ ០៤៦ ដង-នាក់ (ករណី) ក្នុងចំណោម កម្មករនិយោជិតប្រមាណជាង ១ ៥៩២ ៥៥៧នាក់ នៃរោងចក្រសហគ្រាសចំនួនជាង ៨ ៥០៨ សហគ្រាស។ ក្រៅពីការងារខាងលើ ប.ស.ស ក៏ត្រូវទទួលបន្ទុកលើការងារចុះបញ្ជីកម្មករនិយោជិតក្រៅប្រព័ន្ធ ដើម្បីទទួលបានសេវាមូលនិធិ សមធម៌-សុខាភិបាល ដែលមកដល់បច្ចុប្បន្នបានចុះបញ្ជីសហគ្រាសចំនួន ២៣ ១៨៣ សហគ្រាស និងកម្មករនិយោជិតចំនួន ១៣៧ ៨៤៥នាក់ និងទទួលរៀបចំបើកប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាល-កម្ពុជា ដល់កម្មករនិយោជិតជាស្ត្រីទាំងក្នុង និងក្រៅប្រព័ន្ធក្រោយសម្រាលកូន ដែលគិតត្រឹមថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ មានកម្មករនិយោជិតជាស្ត្រីសម្រាលកូនសរុបចំនួន ៥៤ ៥៦៩ នាក់ កូនចំនួន ៥៤ ៩៧៦ នាក់ និងចំណាយទឹកប្រាក់ចំនួន ២១ ៩៩០ ៤០០ ០០០រៀល។

នេះសបញ្ជាក់ពីការយកចិត្តទុកដាក់បំផុត ពីសំណាក់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាចំពោះសុខុមាលភាព និងជីវភាពរស់នៅរបស់មន្ត្រីសាធារណៈទាំងអស់ដែលជានិយោជិតរបស់រដ្ឋ។






**ឯកឧត្តម ប្រតិត្ថ** បានថ្លែងបញ្ជាក់បន្ថែមថា ៖ ប.ស.ស នឹងបន្តពង្រឹង និង ពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ បន្តជម្រុញការអនុវត្តផ្នែកថែទាំសុខភាពទាំងសម្រាប់កម្មករនិយោជិត មន្ត្រីសាធារណៈ និងខិតខំរៀបចំដាក់ឱ្យដំណើរការផ្នែកប្រាក់ សោធនសម្រាប់កម្មករនិយោជិតនិងផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈនៅក្នុងឆ្នាំ២០១៩។



**ឯកឧត្តម នរៈ រតនវឌ្ឍនោ** រដ្ឋលេខាធិការ និងជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ហ៊ឹម ឆែម** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនាបានលើកឡើងថា របបសន្តិសុខសង្គម ផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់ មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការនិងអតីតយុទ្ធជន គឺជាគោលនយោបាយដ៏ល្អមួយក្នុងការឆ្លើយតបទៅនឹងការរក្សាសុខមាលភាព និងលើកកម្ពស់ជីវភាពរស់នៅរបស់មន្ត្រីរាជការ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនឱ្យកាន់តែល្អប្រសើរឡើង ៕



# ប.ស.ស ផ្តល់ការពិនិត្យ និងព្យាបាលជំងឺមហារីកដល់សមាជិក ប.ស.ស ទាំងស្រុង ខណៈដែលសេវានេះបណ្តាប្រទេសមួយចំនួននៅអាស៊ានមិនទាន់ផ្តល់ជូននៅឡើយ




ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសង្គម (ប.ស.ស) **ឯកឧត្តម អ៊ុក សមវិទ្យា** បានថ្លែងថា ប.ស.ស បានផ្តល់ការពិនិត្យ និងព្យាបាលជំងឺមហារីកដល់សមាជិក ប.ស.ស ទាំងស្រុង ដោយរាប់តាំងពីការព្យាបាលដោយកាំរស្មី ការប្រើប្រាស់ថ្នាំគីមី និងការវះកាត់ផងដែរ នៅក្នុងខណៈដែលសេវានេះបណ្តាប្រទេសមួយចំនួននៅអាស៊ានមិនទាន់ហ៊ានផ្តល់នៅឡើយ។





**ឯកឧត្តម**ប្រតិភូរាជរដ្ឋាភិបាលលើកឡើងយ៉ាងដូច្នេះ នៅក្នុងកម្មវិធីប្រគល់ប័ណ្ណ សមាជិក ប.ស.ស ជូនដល់ថ្នាក់ដឹកនាំមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងបរិស្ថាន ចំនួន ២៦៩៩ប័ណ្ណ ដែលរៀបចំឡើងនៅទីស្តីការក្រសួងបរិស្ថាន ក្រោមអធិបតីភាព **លោកជំទាវ ព្រំ សុគី** អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីតំណាង អង្គភាព ស្ថាប័ន ក្រោមឱវាទ សរុបប្រមាណជា ១៥០នាក់ នៅថ្ងៃអង្គារ ៥រោច ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០១៨។

ទាក់ទងទៅនឹងការផ្ដល់សេវាថែទាំសុខភាពជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យានេះ **ឯកឧត្ដម ប្រតិភូ** បានថ្លែងរំលឹកថា៖ ចាប់តាំងពីឆ្នាំ២០០៨ រហូតមកដល់បច្ចុប្បន្ន ប.ស.ស បានពង្រីកវិសាលភាពរបស់ខ្លួនគ្រប ដណ្ដប់ទូទាំងប្រទេសដោយមានមន្ត្រីរាជការ និងបុគ្គលិកដែល កំពុងបម្រើការងារសរុប ចំនួន ១ ៤៧៣នាក់ ក្នុងនោះមានមន្ត្រីរាជការចំនួន ២២៣នាក់ និងបុគ្គលិកជាប់កិច្ចសន្យាចំនួន ១២៥០នាក់។ អនុលោមតាមប្រកាសអន្តរក្រសួងលេខ ២៩១ ក.ប/ប្រ.កចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីកិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្ដល់សេវាសុខាភិបាលរវាងបេឡាជាតិរបបសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាលសម្រាប់ផ្នែកថែទាំសុខភាព ប.ស.ស បានចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលចាប់ពីថ្នាក់មណ្ឌលសុខភាព រហូតដល់ថ្នាក់ជាតិចំនួន ១៣៣៥ មូលដ្ឋានសុខាភិបាល នៅក្នុងនោះមានមន្ទីរពេទ្យរដ្ឋចំនួន ១២៩២ និងមន្ទីរពេទ្យឯកជនចំនួន៤៣។









**ឯកឧត្ដម** ប្រតិភូ បានថ្លែងបន្តទៀតថា៖ តាមរយៈការអនុវត្តរបបសន្តិសុខសង្គម សម្រាប់វិស័យឯកជនប្រកបដោយជោគជ័យគួរជាទីមោទនៈកន្លងមក ប.ស.ស ត្រូវបានរាជរដ្ឋាភិបាលផ្ដល់ទំនុកចិត្ត និងបានប្រគល់ភារកិច្ចបន្ថែមជាប្រតិបត្តិករតែមួយគត់ក្នុងការគ្រប់គ្រងនិងចាត់ចែងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈនិងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន មានបញ្ញត្តិនៅក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧។

នៅដើមឆ្នាំ២០១៨ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន បានដាក់ឱ្យដំណើការ នូវសេវាតាវកាលិករួមមាន៖

– សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ

– សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះ ចំពោះករណីសង្គ្រោះបន្ទាន់

– សេវាបញ្ជូនសព និង សេវាបង្ការសុខភាព។

គិតរហូតមកដល់ពេលនេះ មានមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ទៅទទួលសេវាសុខភាពបានចំនួន ២ ២០១ ដង-នាក់ (ករណី)។ នេះសបញ្ជាក់ពីការយកចិត្តទុកដាក់បំផុត ពីសំណាក់ប្រមុខរាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិត ដ៏ខ្ពង់ខ្ពស់របស់ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះសុខុមាលភាព និងជីវភាពរស់នៅរបស់មន្ត្រីសាធារណៈទាំងអស់ដែលជានិយោជិតរបស់រដ្ឋ។

**ឯកឧត្តម** ប្រតិភូ បានថ្លែងបន្តថា៖ គិតមកដល់បច្ចុប្បន្ននេះ ប.ស.ស បានផ្តល់តាវកាលិកផ្នែកហានិភ័យការងារដល់ជនរងគ្រោះជាកម្មករនិយោជិត សរុបចំនួន ២១៤ ៣៧០នាក់ ក្នុងចំណោមកម្មករនិយោជិតជាសមាជិក ចំនួន១ ៤៨៧ ៤៩១នាក់ នៃរោងចក្រ សហគ្រាស ចំនួន ១២ ៦៨៨សហគ្រាស។ ដោយឡែកសម្រាប់ផ្នែកថែទាំសុខភាព បានផ្តល់សេវាដល់កម្មករនិយោជិតប្រមាណជាង ១ ៨៥២ ០៤៦ ដង-នាក់ (ករណី) ក្នុងចំណោមកម្មករនិយោជិតប្រមាណជាង ១ ៥៩២ ៥៥៧នាក់ នៃរោងចក្រ សហគ្រាស ចំនួនជាង ៨ ៥០៨។ ក្រៅពីការងារខាងលើ ប.ស.ស ត្រូវទទួលបន្ទុកលើការងារចុះបញ្ជីកម្មករនិយោជិតក្រៅប្រព័ន្ធ ដើម្បីទទួលបានសេវាមូលនិធិសមធម៌សុខាភិបាល ដែលមកដល់ពេលនេះ បានចុះបញ្ជីសហគ្រាសចំនួន ២៣ ១៨៣ សហគ្រាស និងកម្មករនិយោជិតចំនួន ១៣៧ ៨៤៥នាក់ និងទទួលរៀបចំបើកប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាល ដល់កម្មករនិយោជិតជាស្ត្រីទាំងក្នុង និងក្រៅប្រព័ន្ធក្រោយសម្រាលកូន ដែលគិតត្រឹមថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ មានកម្មករនិយោជិតជាស្ត្រីសម្រាលកូនចំនួន ៥៦ ៧៨៥នាក់ កូនចំនួន ៥៧ ២១៣ នាក់។

**ឯកឧត្តម** ប្រតិភូបានថ្លែងបញ្ជាក់បន្ថែមថា៖ ប.ស.ស នឹងបន្តពង្រឹងនិងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ នឹងបន្តជំរុញការអនុវត្តផ្នែកថែទាំសុខភាពទាំងសម្រាប់កម្មករនិយោជិត និងមន្ត្រីសាធារណៈ និងខិតខំរៀបចំដាក់ឱ្យដំណើរការផ្នែកប្រាក់សោធន សម្រាប់កម្មករនិយោជិតនិងផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈនៅឆ្នាំ២០១៩។



ផ្តើមចេញពីនេះ **លោកជំទាវ ព្រំ សុភី** មានប្រសាសន៍ថា៖ ការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីរាជការ និងផ្នែកថែទាំសុខភាព សម្រាប់មន្ត្រីក្រសួងបរិស្ថាន អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន គឺជាជោគជ័យថ្មីមួយទៀតរបស់រាជរដ្ឋាភិបាលដែលបានផ្តល់ជូន មន្ត្រីក្រសួងបរិស្ថាននូវការគាំពារសង្គម និងការធានានូវសន្តិសុខសង្គម ព្រមទាំងសេដ្ឋកិច្ចជូនមន្ត្រីរាជការដែលកំពុងបំពេញការងារ និងអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដែលបានតស៊ូបំពេញការងារជូនជាតិមាតុភូមិ នាពេលកន្លងមកឱ្យចាកផុតពីហានិភ័យនៅពេលពួកគាត់ជួបប្រទះបញ្ហាផ្សេងៗពាក់ព័ន្ធនឹងសុខភាពឬគ្រោះថ្នាក់ជាយថាហេតុណាមួយ៕









# បេឡាជាតិរបបសន្តិសុខសង្គម ផ្តល់ប័ណ្ណសមាជិក ប.ស.ស ចំនួនជាង ៦ពាន់ប័ណ្ណ លើកទី១ សម្រាប់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួង-ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយ ក្រសួង-កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានរៀបចំពិធីផ្សព្វផ្សាយខ្លឹមសារអនុក្រឹត្យលេខ៥៩ អនក្រ.បក និងផ្តល់ប័ណ្ណសមាជិក ប.ស.ស ជូនដល់មន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យានៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលប្រព្រឹត្តទៅនៅថ្ងៃពុធ ៧រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០១៨ ស្ថិតនៅក្នុងសាលប្រជុំ នៃក្រសួង-កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ពិធីប្រគល់ប័ណ្ណខាងលើនេះប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម នុត ច័ន្ទសុខា** រដ្ឋលេខាធិការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូ-រាជរដ្ឋាភិបាល ទទួលបន្ទុកជានាយក ប.ស.ស នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈព្រមទាំងមានការអញ្ជើញចូលរួមពីតំណាង ស្ថាប័ន អង្គភាព ពាក់ព័ន្ធនានា សរុបប្រមាណជាង ៧០នាក់។





**ឯកឧត្តម នុត ច័ន្ទសុខា** បានថ្លែងថា នេះជាលើកដំបូងហើយ ដែលបេឡាជាតិរបបសន្តិសុខសង្គម បានផ្តល់ប័ណ្ណសមាជិក ប.ស.ស ជាង ៦ពាន់ប័ណ្ណ សម្រាប់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានមន្ត្រីរាជការសាធារៈ សរុបចំនួន ៧ ៨៥៣នាក់ ក្នុងនោះមន្ត្រីរាជការស៊ីវិលមានចំនួន ៦ ៨២៩ នាក់ និងមន្ត្រីជាប់កិច្ចសន្យាចំនួន ១ ០២៤នាក់ ដែលនឹងត្រូវទទួលបានប័ណ្ណសមាជិក ប.ស.ស សម្រាប់ប្រើប្រាស់ក្នុងការទៅទទួលសេវាពិនិត្យ និងព្យាបាលជំងឺនៅតាមគ្រឹះស្ថានសុខាភិបាលនានា។

ក្នុងឱកាសនោះដែរ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស បានថ្លែងបញ្ជាក់ថា បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) គឺជាគ្រឹះស្ថានសាធារណៈរដ្ឋបាលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនិងស្ថិតនៅក្រោមអាណាព្យាបាល ហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៧និងបានចាប់ផ្តើមដំណើរការចុងឆ្នាំ២០០៨។

តាមរយៈការអនុវត្តរបបសន្តិសុខសង្គមសម្រាប់វិស័យឯកជនប្រកបដោយជោគជ័យគួរជាទីមោទនៈកន្លងមក ប.ស.ស ត្រូវបានរាជរដ្ឋាភិបាលផ្តល់ទំនុកចិត្តនិងបានប្រគល់ភារកិច្ចបន្ថែមជាប្រតិបត្តិករតែមួយគត់ក្នុងការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន មានបញ្ញត្តិនៅក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧។ នេះសបញ្ជាក់អំពីការយកចិត្តទុកដាក់បំផុតពីសំណាក់ប្រមុខដឹកនាំនៃរាជរដ្ឋាភិបាលកម្ពុជា គឺសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ចំពោះសុខុមាលភាព និងជីវភាពរស់នៅរបស់មន្ត្រីសាធារណៈទាំងអស់ដែលជានិយោជិតរបស់រដ្ឋ។

នៅដើមឆ្នាំ២០១៨របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនបានដាក់ឱ្យដំណើការ នូវសេវាតាវកាលិករួមមាន៖

- សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ
- សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះចំពោះករណីសង្គ្រោះបន្ទាន់
- សេវាបញ្ជូនសព និង សេវាបង្ការសុខភាព ។





មកដល់បច្ចុប្បន្ន មានមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ទៅទទួលសេវាសុខភាពបានចំនួន ១៨ ៣២៥ដង/នាក់ (ករណី)។ រហូតមកដល់បច្ចុប្បន្ននេះទៀត ប.ស.ស បានផ្តល់តាវកាលិកផ្នែកហានិភ័យការងារដល់ជនរងគ្រោះជាកម្មករនិយោជិតចំនួន ២១៣ ០២៥នាក់ក្នុងចំណោមកម្មករនិយោជិតជាសមាជិកចំនួន ១ ៤៨០ ៩៣២នាក់នៃរោងចក្រ សហគ្រាសចំនួន ១២ ៥៨៨សហគ្រាស។ដោយឡែកសម្រាប់ផ្នែកថែទាំសុខភាព បានផ្តល់សេវាដល់កម្មករនិយោជិតប្រមាណជាង ១ ៥៩០ ៥៨២ដង/នាក់ (ករណី)ក្នុងចំណោមកម្មករនិយោជិតប្រមាណជាង ១ ៨០៩ ០៥០នាក់ នៃរោងចក្រសហគ្រាសចំនួនជាង ៨ ២៦៩ សហគ្រាស៕





# សិក្ខាសាលា ស្តីពីការពង្រីកវិសាលភាពគាំពារសង្គម ដល់កម្មករនិយោជិតលើវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា

នៅថ្ងៃអង្គារ ២កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័កព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៨ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គមបានអញ្ជើញចូលរួមជាអធិបតីក្នុងកម្មវិធីសិក្ខាសាលាស្តីពីការពង្រីកវិសាលភាពគាំពារសង្គមដល់កម្មករនិយោជិតលើវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា នៅសណ្ឋាគារហ៊ីម៉ាវ៉ារី។





កម្មវិធីនេះមានការអញ្ជើញចូលរួមពីតំណាង ប.ស.ស តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងក្រសួងសុខាភិបាល តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តំណាងក្រសួងផែនការ តំណាងអគ្គនាយកដ្ឋានពន្ធដារតំណាងនាយកដ្ឋានពេទ្យការងារតំណាងសមាគមអ្នកសាងសង់កម្ពុជា (CCA) តំណាងសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្ម (CAMFEBA) និង (GMAC) កម្មវិធីប្រព័ន្ធគាំពារសង្គមនៃសហគមន៍អឺរ៉ុប (EU-SPS) និងតំណាងសហជីព សរុបប្រមាណ ៥០ នាក់។

ថ្លែងទៅកាន់អង្គពិធី **ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាល បានបញ្ជាក់ថា ដើម្បីឆ្លើយតបនឹងតម្រូវការសង្គម និងសេចក្តីសង្ឃឹមរបស់ប្រជាជនកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនៅក្នុងអាណត្តិទី៦ នៃរដ្ឋសភា ដែលជាគោលនយោបាយជាតិគាំពារសង្គម ទាក់ទងទៅនិង កម្មករនិយោជិត ដែលមិនសំដៅតែសម្រាប់វិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធនោះទេ សូម្បីតែសេដ្ឋកិច្ច ក្រៅប្រព័ន្ធ ក៏ពួកគាត់មានសិទ្ធិទទួលបានការគាំពារសង្គម ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈការផ្តល់នូវរបបសន្តិសុខសង្គម ពីបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)ផងដែរ ។








**ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាល បានបន្ថែមថា របប-សន្តិសុខសង្គមបានផ្តល់នូវអត្ថប្រយោជន៍យ៉ាងច្រើនដល់កម្មករនិយោជិតទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធនៅកម្ពុជា ដោយអាចធានាបាន នូវសន្តិសុខប្រាក់ចំណូល ដល់ពួកគាត់ នៅពេលដែលមានហានិភ័យការងារ គ្រោះថ្នាក់ការងារ ឬក៏មានជំងឺកើតឡើងជាយថាហេតុ។

**ឯកឧត្តម** បានបញ្ជាក់បន្ថែមទៀតថា វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក៏បានរួមចំណែកយ៉ាងសំខាន់ក្នុងការចូលរួមលើកកម្ពស់ចំណូលនៃថវិកាជាតិដូចវិស័យផ្សេងៗដែរ ដូច្នេះ ប.ស.ស និងអង្គការ ILO បានសហការគ្នាប្រជុំផ្ទាល់ជាមួយជំនាញ និងស្ថាប័នពាក់ព័ន្ធទាំងអស់នេះ ដើម្បីប្រមូលធាតុចូលសំខាន់ៗសម្រាប់ឈានដល់ការពង្រីកវិសាលភាពគាំពារសង្គម ដល់កម្មករនិយោជិតក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា។

**ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាល បានថ្លែងអំណរគុណចំពោះ ភាគីពាក់ព័ន្ធទាំងអស់ ដែលខិតខំរួម ចំណែកកសាងសមិទ្ធផលយ៉ាងច្រើនសម្រាប់ការអនុវត្តរបបសន្តិសុខសង្គម ប៉ុន្តែយ៉ាងណាក៏ដោយ **ឯកឧត្តម** បានស្នើឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់បន្តកិច្ចសហការគ្នា ពង្រឹង និងពង្រីក របបសន្តិសុខសង្គមឱ្យស្របទៅតាមផែនការដែលបានគ្រោងទុក៕



# គិតត្រឹមឆមាសទី១ ឆ្នាំ២០១៨

## មានមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ទៅទទួលសេវាថែទាំសុខភាព សរុបប្រមាណជា ៨ ៧២៧ដង-នាក់

ការថ្លែងពីសំណាក់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម យ៉ាងដូច្នេះ នៅក្នុងពិធីប្រជុំផ្សព្វផ្សាយស្តីពីនីតិវិធី និងបែបបទ ទទួលសេវាថែទាំសុខភាព សម្រាប់មន្ត្រីរាជការ និង បុគ្គលិកជាប់កិច្ចសន្យា នៃបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលបានប្រព្រឹត្តិទៅនៅសាលា ប្រជុំធំនៃបេឡាជាតិរបបសន្តិសុខសង្គម។

**ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាល បានថ្លែងបញ្ជាក់ថា មកដល់ពេលនេះមាន មូលដ្ឋានសុខាភិបាលសាធារណៈ និងមន្ទីរពេទ្យឯកជន ចំនួន ១ ៣២៧ មូលដ្ឋាន ហើយបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ក្នុងនោះ សម្រាប់ ឆមាសទី១ ឆ្នាំ២០១៨ នេះ គឺមានមន្ត្រីសាធារណៈ អតីត មន្ត្រីរាជការ និងអតីតយុទ្ធជន ទៅទទួល សេវា ថែទាំ សុខភាព សរុបប្រមាណជា ៨ ៧២៧ដង-នាក់ ដោយ ប.ស.ស បាន ចំណាយថវិកាសរុបប្រមាណ ៥ ៩៧៣ ២៩៧ លានរៀល។

**ឯកឧត្តម** ប្រតិភូរាជដ្ឋាភិបាល ក៏បានថ្លែងរំលឹកផងដែរ ទៅដល់បងប្អូនជាមន្ត្រីរាជការទាំងអស់ ទៅទទួលសេវាពិនិត្យព្យាបាល និងថែទាំវេជ្ជសាស្ត្រ នៅតាមមន្ទីរពេទ្យជាដៃគូរបស់ ប.ស.ស ត្រូវស្វែររកភ្នាក់ងារ ប.ស.សដែលប្រចាំការនៅតាមមន្ទីរពេទ្យទាំងនោះ ដើម្បីឱ្យពួកគាត់ជួយធ្វើការសម្របសម្រួលជាមួយក្រុមគ្រូពេទ្យ ក្នុងការពិនិត្យព្យាបាលជំងឺជូន ដោយជៀសវាងភាពខុសប្រក្រតីណាមួយបានកើតឡើង ។ក្រៅពីនេះលោក លោកស្រី ក៏អាចជូនដំណឹងភ្លាមៗមកលេខ ១២៨៦ ពីគ្រប់ប្រព័ន្ធទូរស័ព្ទដោយឥតគិតថ្លៃសម្រាប់បម្រើសេវា និងសម្របសម្រួលជូនបងប្អូនជាសមាជិក ប.ស.ស ២៤ម៉ោង លើ ២៤ម៉ោង ជារៀងរាល់ថ្ងៃ។

គួរបញ្ជាក់ផងដែរថា រាជរដ្ឋាភិបាលបានផ្តល់ភារកិច្ចថ្មីដល់ ប.ស.ស ក្នុងការអនុវត្តរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ចាប់តាំងពី ខែមករាឆ្នាំ២០១៨មកម្លេះដើម្បីពង្រីកប្រព័ន្ធគាំពារសង្គមជូនដល់មន្ត្រីសាធារណៈអតីតមន្ត្រីរាជការ និងអតីតយុទ្ធជនឱ្យទទួល បានសេវាថែទាំសុខភាពដោយឥតគិតថ្លៃ ដូចបងប្អូនកម្មករ៕

# ប័ណ្ណសមាជិក ប.ស.ស ចំនួន ៧៩៤ ប័ណ្ណបាន ផ្តល់ជូនមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៅក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច



**ឯកឧត្តម ម៉េង ហុង** នាយករង ប.ស.ស តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ិក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា នាយក ប.ស.ស បានបញ្ជាក់ថា កន្លងមក ប.ស.ស បានសហការតាមបណ្តាក្រសួងមួយចំនួនរួចមកហើយ ក្នុងការផ្តល់ប័ណ្ណ សមាជិក ប.ស.ស ទៅដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា។ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បន្តសហការជាមួយក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ផ្តល់ប័ណ្ណសមាជិករបស់ខ្លួន ជូនដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាចំនួន ៧៩៤ប័ណ្ណ ដើម្បីឱ្យពួកគាត់ទទួលបានសេវាថែទាំសុខភាពនៅមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ។





**ឯកឧត្តម** នាយករង បានបន្តថា ចាប់ពីឆ្នាំ២០០៨ រហូតមកដល់បច្ចុប្បន្ន ប.ស.ស បានពង្រីកវិសាលភាពរបស់ខ្លួនគ្របដណ្តប់ទូទាំងប្រទេស ដោយមានមន្ត្រីរាជការ និងបុគ្គលិកដែលកំពុងបម្រើការងារសរុប ចំនួន១៣៥៩នាក់ ក្នុងនោះមានមន្ត្រីរាជការ ចំនួន២២៣នាក់ និងបុគ្គលិកជាប់កិច្ចសន្យា ចំនួន ១ ១៣៦នាក់។

**ឯកឧត្តម** នាយករង បានថ្លែងរំលឹកបន្តថា៖ តាមរយៈការអនុវត្តរបបសន្តិសុខសង្គមសម្រាប់វិស័យឯកជនប្រកបដោយជោគជ័យគួរជាទីមោទនៈ កន្លងមក ប.ស.ស ត្រូវបានរាជរដ្ឋាភិបាលផ្ដល់ទំនុកចិត្ត និងបានប្រគល់ភារកិច្ចបន្ថែមជាប្រតិបត្តិករតែមួយគត់ក្នុងការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន មានបញ្ញត្តិនៅក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ។ នៅដើមឆ្នាំ២០១៨ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន បានដាក់ឱ្យដំណើរការ នូវកញ្ចប់តាវកាលិករួមមាន៖

– សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ
– សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះចំពោះករណីសង្គ្រោះបន្ទាន់
– សេវាបញ្ជូនសព និងសេវាបង្ការសុខភាព។

គិតរហូតមកដល់ពេលនេះ មានមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ទៅទទួលសេវាសុខភាពបានចំនួន ២ ២០១ ដង-នាក់ ។ នេះសបញ្ជាក់ពីការយកចិត្តទុកដាក់បំផុត ពីសំណាក់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះសុខុមាលភាពនិងជីវភាពរស់នៅរបស់មន្ត្រីសាធារណៈទាំងអស់ដែលជានិយោជិតរបស់រដ្ឋ។



**ឯកឧត្តម** នាយករង លើកឡើងក្នុងពិធីប្រគល់-ទទួលប័ណ្ណ សមាជិក ប.ស.ស ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចំនួន ៧៩៤ប័ណ្ណ នៅសាលប្រជុំទីស្តីការក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ចាប សុថារិទ្ធ** រដ្ឋលេខាធិការ និងជាតំណាងដ៏ខ្ពង់ខ្ពស់ **លោកជំទាវ កិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនង រដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ព្រមទាំងមានវត្តមានចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីតំណាងអង្គភាព ស្ថាប័ន ក្រោមឱវាទ សរុបប្រមាណជិត ១០០នាក់ កាលពីថ្ងៃព្រហស្បតិ៍ ៦កើត ខែមិគសិរ ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨ កន្លងមកនេះ ៕





# ប.ស.ស ប្រគល់ប័ណ្ណសមាជិករបស់ខ្លួន ចំនួន ៨១០ប័ណ្ណ ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងរ៉ែ និងថាមពល




បេឡាជាតិរបបសន្តិសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយក្រសួងរ៉ែ និងថាមពល បានរៀបចំពិធីប្រគល់-ទទួលប័ណ្ណសមាជិក ប.ស.ស និងផ្សព្វផ្សាយអំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និង មន្ត្រីជាប់កិច្ចសន្យា នៃក្រសួងរ៉ែ និង ថាមពល ដែលប្រព្រឹត្តទៅនៅថ្ងៃសុក្រ ១៤ កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៨ នៅទីស្តីការក្រសួងរ៉ែ និងថាមពល។






**ឯកឧត្តម ស៊ុំ សោភ័ណ** នាយករងនៃបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស) បានថ្លែងក្នុងអង្គពិធីថា មកដល់ថ្ងៃនេះ ប.ស.ស បានប្រគល់ប័ណ្ណសមាជិករបស់ខ្លួនជូនដល់មន្ត្រីសាធារណៈ បានចំនួន ១៤ក្រសួងរួចមកហើយ នៅថ្ងៃនេះដែរ ប.ស.ស បានបន្តសហការជាមួយបណ្តាក្រសួងផ្សេងទៀត ក្នុងការផ្តល់ប័ណ្ណសមាជិក ប.ស.ស ជូនដល់មន្ត្រីសាធារណៈ ដែលមិនទាន់មានប័ណ្ណ ប.ស.ស សម្រាប់ទៅទទួលសេវារបបសន្តិសុខសង្គម នៅតាមមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ។

**ឯកឧត្តម** នាយករង បានថ្លែងបន្តទៀតថា អនុលោមតាមប្រកាសអន្តរក្រសួងលេខ ២៩១ ក.ប/ប្រ.ក ចុះថ្ងៃទី២៥ ខែកក្កដាឆ្នាំ២០១៦ ស្តីពីកិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាល រវាងបេឡាជាតិរបបសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាលសម្រាប់ផ្នែកថែទាំសុខភាព ប.ស.ស បាន ចុះកិច្ចព្រម ព្រៀង ជាមួយ មូល ដ្ឋាន សុខាភិបាល ចាប់ពីថ្នាក់មណ្ឌលសុខភាព រហូតដល់ថ្នាក់ជាតិសរុបចំនួន ១៣៣៥ មូល ដ្ឋាន សុខាភិបាល នៅក្នុងនោះមានមន្ទីរពេទ្យរដ្ឋចំនួន ១ ២៩២ និងមន្ទីរពេទ្យឯកជនចំនួន៤៣ ដែលគ្រប់សមាជិក ប.ស.ស ទាំងអស់អាចទៅទទួលសេវាពិនិត្យ និងព្យាបាលជំងឺដោយឥតបង់ថ្លៃ ។

**ឯកឧត្តម** នាយករង បានបញ្ជាក់បន្ថែមថា គិតចាប់ពីពេលដំណើរការដំបូងក្នុងឆ្នាំ២០០៨ រហូតមកដល់បច្ចុប្បន្ន ប.ស.ស បានផ្តល់តាវកាលិក ៖

– ផ្នែកហានិភ័យការងារ ដល់ជនរងគ្រោះជាកម្មករនិយោជិតចំនួន ២១៦ ៣៥៧នាក់ ក្នុងចំណោមកម្មករនិយោជិតជាសមាជិកចំនួន ១ ៦១៤ ៣៣៩នាក់ នៃសហគ្រាសចំនួន ១២ ៦៨៨សហគ្រាស។

– ផ្នែកថែទាំសុខភាព បានផ្តល់សេវាដល់កម្មករនិយោជិតចំនួន ១ ៨៥០ ៧១៩ដង-នាក់ ក្នុងចំណោមកម្មករនិយោជិតប្រមាណជាង ១ ៦១៤ ៣៣៩នាក់ នៃសហគ្រាស ចំនួនជាង ១០ ១៥២ សហគ្រាស។











**ឯកឧត្តម** នាយករង បានបន្តទៀតថា ប.ស.ស បានចុះបញ្ជីមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនសរុបចំនួន ៣១៤ ០៧៦នាក់ ក្នុងនោះមន្ត្រីរាជការចំនួន ២០៤ ០៨៤នាក់ អតីតមន្ត្រីរាជការចំនួន ៥៥ ២២២នាក់ និងអតីតយុទ្ធជន សរុបចំនួន ៥៤ ៧៧០នាក់ ។ បច្ចុប្បន្ន មានមន្ត្រីសាធារណៈអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន បានទៅទទួលសេវាថែទាំសុខភាព នៅតាមមូលដ្ឋានសុខាភិបាលដែលជាដៃគូជាមួយ ប.ស.ស បានចំនួន ២២ ០០១ដង-នាក់។ ប.ស.ស នឹងបន្តពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារនិងបន្តជំរុញការអនុវត្តផ្នែកថែទាំសុខភាពទាំងសម្រាប់កម្មករនិយោជិត និងមន្ត្រីសាធារណៈ និងខិតខំរៀបចំដាក់ឱ្យដំណើរការ ផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកប្រាក់សោធនសម្រាប់កម្មករនិយោជិតនៅឆ្នាំ២០១៩៕



# បេឡាជាតិរបបសន្តិសុខសង្គម បានផ្តល់ប័ណ្ណសមាជិករបស់ខ្លួន ចំនួន ១៦២១ប័ណ្ណ ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងពាណិជ្ជកម្ម

បេឡាជាតិរបបសន្តិសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយក្រសួងពាណិជ្ជកម្ម បាន រៀប ចំពិធីប្រគល់-ទទួលប័ណ្ណសមាជិក ប.ស.ស និង ផ្សព្វផ្សាយអំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និង មន្ត្រីជាប់កិច្ចសន្យា នៃក្រសួង ពាណិជ្ជកម្ម ដែលប្រព្រឹត្តទៅនៅថ្ងៃអង្គារ ១៣កើត ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅទីស្តីការក្រសួងផ្ទាល់។



លោក ស៊ុំ សោភ័ណ នាយករងនៃបេឡាជាតិរបបសន្តិសុខសង្គម



ពិធីនេះប្រព្រឹត្តិទៅក្រោមអធិបតីភាព **ឯកឧត្តម ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួង ពាណិជ្ជកម្ម **លោក ស៊ុំ សោភ័ណ** នាយករងនៃបេឡាជាតិរបបសន្តិសុខសង្គម និងជាតំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម អ៊ុក សមវិទ្យា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម ព្រមទាំងមានការអញ្ជើញចូលរួមពី ថ្នាក់ដឹកនាំ និងមន្ត្រីតំណាង ស្ថាប័ន អង្គភាព ក្រោមឱវាទសរុបប្រមាណជា ២០០នាក់។

**ឯកឧត្តម ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មបានលើកឡើងថា៖ នេះជាលើកដំបូងហើយ ដែលបេឡាជាតិរបបសន្តិសុខសង្គម បានផ្តល់ប័ណ្ណសមាជិក ប.ស.ស សម្រាប់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងពាណិ-ជ្ជកម្ម។ **ឯកឧត្តម** បានបន្តទៀតថា៖ របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ សម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រី សាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន គឺជាគោលនយោបាយដ៏ល្អមួយក្នុងការឆ្លើយតបទៅនឹងការរក្សាសុខុមាលភាព និងលើកកម្ពស់ជីវភាពរស់នៅរបស់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនឱ្យកាន់តែល្អប្រសើរឡើង។





**លោក ស៊ុំ សោភ័ណ** នាយករងនៃបេឡាជាតិរបបសន្តិសុខសង្គម បានថ្លែងថា៖ គោលបំណងនៃពិធីនេះ គឺដើម្បីផ្តល់ប័ណ្ណសមាជិក ប.ស.ស ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងពាណិជ្ជកម្ម សម្រាប់ទៅទទួលសេវារបបសន្តិសុខសង្គម នៅតាមមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស និង ផ្សព្វផ្សាយអំពីគោលនយោបាយរបបសន្តិសុខសង្គម សម្រាប់មន្ត្រីរាជការ និងកម្មករនិយោជិតផងដែរ។



ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**លោកនាយករង** បានថ្លែងបន្តទៀតថា៖ ចាប់តាំងពីឆ្នាំ ២០០៨ រហូតមកដល់បច្ចុប្បន្ន ប.ស.ស បានពង្រីកវិសាលភាពរបស់ខ្លួនគ្រប់ដណ្តប់ទូទាំងប្រទេសដោយមានមន្ត្រីរាជការ និងបុគ្គលិកដែលកំពុងបម្រើការងារសរុបចំនួន ១ ៤៧៣នាក់ ក្នុងនោះមានមន្ត្រីរាជការចំនួន ២២៣នាក់ និងបុគ្គលិកជាប់កិច្ចសន្យាចំនួន ១ ២៥០នាក់។ អនុលោមតាមប្រកាសអន្តរក្រសួងលេខ ២៩១ ក.ប/ប្រ.ក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីកិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាល រវាងបេឡាជាតិរបបសន្តិសុខសង្គម និងមូលដ្ឋាន សុខាភិបាល សម្រាប់ផ្នែកថែទាំសុខភាព ប.ស.ស បានចុះកិច្ចព្រមព្រៀង ជាមួយមូលដ្ឋានសុខាភិបាលចាប់ពីថ្នាក់មណ្ឌលសុខភាពរហូតដល់ថ្នាក់ជាតិចំនួន ១៣៣៥ មូលដ្ឋានសុខាភិបាល នៅក្នុងនោះមានមន្ទីរពេទ្យរដ្ឋចំនួន ១ ២៩២ និងមន្ទីរពេទ្យឯកជនចំនួន ៤៣ ។



**លោក ស៊ុំ សោភ័ណ** បានបញ្ជាក់បន្ថែមថា៖ ក្រៅពីការងារខាងលើ ប.ស.ស ក៏ត្រូវទទួលបន្ទុកលើការងារចុះបញ្ជីកម្មករនិយោជិត ក្រៅប្រព័ន្ធ ដើម្បីទទួលបានសេវាមូលនិធិសមធម៌សុខាភិបាល ដែលមកដល់បច្ចុប្បន្ន បានចុះបញ្ជីសហគ្រាសចំនួន ២៣១៨៣សហគ្រាស និងកម្មករនិយោជិតចំនួន ១៣៧ ៨៤៥នាក់ និងទទួលរៀបចំបើកប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលកម្ពុជា ដល់កម្មករនិយោជិតជា ស្ត្រីទាំងក្នុង និងក្រៅប្រព័ន្ធ ក្រោយសម្រាលកូន ដែលគិតត្រឹមថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ២០១៨ មានកម្មករនិយោជិតជាស្ត្រីសម្រាលកូនសរុបចំនួន ៥៥៦៩៥នាក់ កូនចំនួន ៥៦១១២នាក់ និង ចំណាយទឹកប្រាក់ចំនួន ២២ ៤៤៤ ៨០០ ០០០រៀល ។





នេះសបញ្ជាក់ពីការយកចិត្តទុកដាក់បំផុត ពីសំណាក់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចំពោះសុខុមាលភាព និងជីវភាពរស់នៅរបស់ មន្ត្រីសាធារណៈទាំងអស់ដែលជានិយោជិតរបស់រដ្ឋ។

**លោក ស៊ុំ សោភ័ណ** បានបន្តទៀតថា ៖ ប.ស.ស នឹងបន្តពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងបន្តជម្រុញការអនុវត្តផ្នែកថែទាំសុខភាព ទាំងសម្រាប់កម្មករនិយោជិត មន្ត្រីសាធារណៈ និងខិតខំរៀបចំដាក់ឱ្យដំណើរការផ្នែកប្រាក់សោធនសម្រាប់កម្មករ-និយោជិត និងផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈនៅក្នុងឆ្នាំ២០១៩ ៕









# ចំនួនអ្នកមានប័ណ្ណបើកបរដឹកកម្មករបានកើនឡើងដល់ ៣ ៥៩១នាក់ ស្មើនឹង ៨២% ក្នុងចំណោមអ្នកបើកបរសរុប ៤ ៣៦៩នាក់ នៅទូទាំងប្រទេស



គិតត្រឹមថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០១៨ ចំនួនអ្នកមានប័ណ្ណបើកបររថយន្តដឹកកម្មករនិយោជិត បានកើនឡើងដល់ ៣ ៥៩១ នាក់ ស្មើនឹង ៨២% នៅសល់ ៣២១ នាក់ស្មើនឹង ៧.៣៥%ប៉ុណ្ណោះ មិនទាន់មានប័ណ្ណបើកបរនៅក្នុងចំណោមអ្នកបើកបររថយន្តដឹកកម្មករនិយោជិតសរុប ៤ ៣៦៩ នាក់នៅក្នុងទូទាំងប្រទេស។





**ឯកឧត្តម ប៉ែន នរៈវុធ** នាយករងបេឡាជាតិរបបសន្តិសុខសង្គម និង ជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា នាយកបេឡាជាតិរបបសន្តិសុខសង្គម កាលថ្ងៃសុក្រ ១៣កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០១៨ បានអញ្ជើញជាអធិបតីក្នុងពិធីចែកប័ណ្ណបើកបរ ដល់អ្នកបើកបរ យានយន្តដឹកកម្មករនិយោជិត នៅរោងចក្រ CARLINGTON (CAMBODIA) CO.,LTD ស្ថិតនៅស្រុកជើងព្រៃ ខេត្តកំពង់ចាម។

**ឯកឧត្តម** បានបញ្ជាក់ថា បើយោងតាមរបាយការណ៍ពីក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) នៃ ប.ស.ស សម្រាប់ខេត្តកំពង់ចាម ឆ្នាំ២០១៨នេះ ក្រុមការងារ ស.ផ.ក បានចុះមករៀបចំប្រឡងផ្តល់ប័ណ្ណបើកបរ ដល់អ្នកបើកបរចំនួន ០៣លើក រួចមកហើយ ដែលមានអ្នកប្រឡងជាប់ជាស្ថាពរ និង ត្រូវទទួលបានប័ណ្ណមានចំនួន ២៣៨នាក់ ក្នុងនោះប្រភេទ "ខ" ចំនួន ១៤៤នាក់ និងប្រភេទ "គ" "ឃ១" និង "ឃ២" ចំនួន ៩៤នាក់។



**នេះជាលើកទី៤** ហើយដែលក្រុមការងារ ស.ផ.ក នៃ ប.ស.ស បានចុះមកបណ្តុះបណ្តាល និងរៀបចំពិធីប្រគល់ប័ណ្ណបើកបរ ដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិតចំនួន៦១នាក់ ជាប្រភេទ "ខ" សរុបអ្នកមានប័ណ្ណ នៅក្នុងខេត្ត ទាំងអស់មានចំនួន ២៩៩នាក់។ ក្នុងខេត្តមួយនេះដែរ មាន រោងចក្រចំនួន ១០ កម្មករនិយោជិតមានចំនួន ២៣ ០៥១នាក់ អ្នកបើកបរសរុប ៣៨៧នាក់ ក្នុងនោះរថយន្ត ៣០៨នាក់ និង រ៉ឺម៉ក ៧៩នាក់ អ្នកមានប័ណ្ណស្របតាមប្រភេទយានយន្ត មាន ចំនួន ១១០នាក់ អ្នកមានប័ណ្ណមិនស្របតាមប្រភេទយានយន្ត មានចំនួន ១៨៥ នាក់អ្នកគ្មានប័ណ្ណបើកបរមានចំនួន៩២នាក់។ សម្រាប់ឆ្នាំ ២០១៨នេះ ចំពោះករណីគ្រោះថ្នាក់ចរាចរណ៍មាន តែ១ករណីប៉ុណ្ណោះ គឺនៅថ្ងៃទី០២ ខែសីហា ដែលមានកម្មករនិយោជិត រងគ្រោះថ្នាក់ចំនួន ០៣នាក់ ក្នុងនោះ ០២នាក់ របួសធ្ងន់ និង ស្លាប់ ០១នាក់។



ជាមួយគ្នានេះដែរ **ឯកឧត្តម** នាយករង បានថ្លែងលើកទឹកចិត្តដល់អ្នកបើកបរយានយន្តដឹក កម្មករនិយោជិតទាំងអស់ឱ្យគោរពក្រមសីលធម៌វិជ្ជាជីវៈ ជំនាញជាអ្នកបើកបរឱ្យបានត្រឹមត្រូវ គ្រប់ពេលវេលា ព្រោះថាអាយុជីវិតកម្មករនិយោជិតទាំងអស់ ត្រូវបានពឹងផ្អែកទៅលើ អ្នកបើកបរយានយន្តទាំងស្រុង ទាំងពេលទៅបំពេញការងារ និងពេលត្រឡប់មកវិញ។ កន្លងមកសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់ថា "ថ្ងៃនេះ ថ្ងៃស្អែកកុំឱ្យមានគ្រោះថ្នាក់ចរាចរ"។





# បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) កម្ពុជា ទទួលបាន ពានរង្វាន់ ស្តីពីការផ្តល់សេវាល្អសម្រាប់របបថែទាំសុខភាព ពីប្រធានសមាគមសន្តិសុខសង្គមអាស៊ាន




បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) កម្ពុជា ទទួលបានពានរង្វាន់ស្តីពីការផ្តល់សេវាល្អសម្រាប់របបថែទាំសុខភាព ពីប្រធាន សមាគមសន្តិសុខសង្គមអាស៊ាន ខាងលើនេះ នៅគ្រាដែល **ឯកឧត្តម ស៊ុំ សោភ័ណ** នាយករងបេឡាជាតិរបបសន្តិសុខសង្គម តំណាង **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម និង សហការីបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសមាគមសន្តិសុខសង្គមអាស៊ានលើកទី៣៥ក្រោមប្រធានបទ "បដិវត្តន៍ផ្នែកឧស្សាហកម្មលើកទី៤និងការអភិវឌ្ឍវិស័យសន្តិសុខសង្គមអាស៊ាន ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨ នៅទីក្រុង Nha Trang ប្រទេសវៀតណាម។







កិច្ចប្រជុំ ត្រូវបានប្រកាសបើកដោយ **ឯកឧត្តម Vu Doc Dam** ឧបនាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងមានការចូលរួមពីសំណាក់ប្រធានសមាគមសន្តិសុខ អាស៊ាន អគ្គលេខាធិការ ថ្នាក់ដឹកនាំស្ថាប័ន សន្តិសុខសង្គម និង តំណាងអង្គទូតបណ្តារដ្ឋជាសមាជិកអាស៊ាន ប្រមាណជាង ២០០នាក់។

គោលបំណងសំខាន់នៃកិច្ចប្រជុំនេះ គឺផ្តោតជាចម្បងទៅលើបញ្ហានិងកាលានុវត្តភាពនៃស្ថាប័នសន្តិសុខសង្គមអាស៊ាន នៅក្នុងបរិបទនៃបដិវត្តន៍ផ្នែកឧស្សាហកម្មលើកទី៤ និងលំហូរសេរីនៃការងារដែលបានបង្កើតជាបញ្ហាក្នុងពេលបច្ចុប្បន្ន។

គួរបញ្ជាក់ផងដែរថា នេះគឺជាខួបគំរប់ ២០ឆ្នាំ នៃការបង្កើតសមាគមមួយនេះឡើងដែលបច្ចុប្បន្នមានសមាជិកជស្ថាប័នសន្តិសុខសង្គម ចំនួន១៩ មកពីប្រទេសអាស៊ានចំនួន១០៕

# វគ្គបណ្ដុះបណ្ដាលស្ដីពី នីតិវិធីចុះបញ្ជិកា នីតិវិធីទាមទារតាវកាលិក និងការទទួលបានអត្ថប្រយោជន៍ ប.ស.ស ដល់ប្រធានរដ្ឋបាល តំណាងអង្គការ សមាគម ប្រមាណជាង ៦០នាក់ នៅសណ្ឋាគារ សាន់វេ រាជធានីភ្នំពេញ




ប្រធាន ការិយាល័យ តាវកាលិក **លោក សុក ប៉ូរ៉ា** និងជាតំណាង **ឯកឧត្ដម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស នៅថ្ងៃសុក្រ ១៣កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៨ បានធ្វើបទបង្ហាញស្ដីពី "បច្ចុប្បន្នភាពរបបសន្តិសុខសង្គម" ដែលរៀបចំឡើង ដោយសមាគមសហគ្រិនកម្ពុជា (សសក) ដែលមានការចូលរួមពីប្រធាន រដ្ឋបាលរោងចក្រតំណាងអង្គការ សមាគម ប្រមាណជាង ៦០នាក់ នៅសណ្ឋាគារ សាន់វេ រាជធានីភ្នំពេញ។






**លោក សុក ប៉ូរ៉ា** បានមានប្រសាសន៍ថា៖ វគ្គបណ្ដុះបណ្ដាលនេះ ធ្វើឡើងក្នុងគោលបំណងផ្សព្វផ្សាយ និងពន្យល់អំពីនីតិវិធីចុះបញ្ជិកា នីតិវិធីទាមទារតាវកាលិក និងការទទួលបានអត្ថប្រយោជន៍ពី ប.ស.ស ។

ប.ស.ស គឺជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលត្រូវបានបង្កើតឡើងដើម្បីធានារ៉ាប់រងសង្គម និងផ្ដល់សំណង (តាវកាលិក) ជូនដល់សមាជិកដែលបានចុះបញ្ជីមកក្នុង ប.ស.ស។

**លោក សុក ប៉ូរ៉ា** បញ្ជាក់ថា៖ ប.ស.ស ផ្ដល់ការធានារ៉ាប់រងសង្គម មានផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ដោយឡែកផ្នែកសោធននឹង ចាប់អនុវត្តនៅឆ្នាំ ២០១៩ ខាងមុខនេះ។

**លោក** បន្តថា នៅពេលបងប្អូនកម្មករនិយោជិតជួបគ្រោះថ្នាក់នៅពេលបំពេញការងារជនរងគ្រោះអាចទៅទទួលការ សង្គ្រោះប ន្ទាន់នៅតាម មូល ដ្ឋាន សុខាភិបាល ដែល បានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ក្នុងនោះរាប់ទាំងការពិនិត្យព្យាបាលនិងថែទាំវេជ្ជសាស្រ្តរហូតដល់ជាសះស្បើយ ដោយឥតបង់ថ្លៃព្រមទាំងទទួលបានប្រាក់ឧបត្ថម្ភបន្ថែមទៀត។ សម្រាប់ផ្នែកថែទាំសុខភាព នៅពេលសមាជិក ប.ស.ស មានជំងឺឬគ្រោះថ្នាក់ក្រៅម៉ោងធ្វើការ គាត់ក៏អាចទៅទទួលសេវា នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈជាដៃគូរបស់ ប.ស.ស ដោយឥតគិតថ្លៃនិងទទួលបានប្រាក់ឧបត្ថម្ភនៅពេលសម្រាកព្យាបាលជំងឺដូចគ្នាផងដែរ។



**លោក សុក ប្ញូរ៉ា** បានអំពាវនាវដល់សហគ្រាសគ្រឹះស្ថានទាំងអស់ដែលមានកម្មករនិយោជិតចាប់ពី១នាក់ឡើងទៅត្រូវចុះបញ្ជិកាមកក្នុង បេឡាជាតិរបបសន្តិសុខសង្គមនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីឱ្យបុគ្គលិកក៏ដូចជាកម្មករ និយោជិតដែលកំពុងបម្រើការងារឱ្យទទួលបានសិទ្ធិទៅប្រើប្រាស់សេវាពិនិត្យព្យាបាលនិងថែទាំវេជ្ជសាស្រ្តនៅតាមមន្ទីរពេទ្យដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ដោយឥតគិតថ្លៃ។



ពិសេស ត្រូវតែចងចាំលេខសង្គ្រោះបន្ទាន់ ១២៨៦ បងប្អូនកម្មករ និយោជិតអាចហៅចូលដោយឥតគិតថ្លៃពីគ្រប់ប្រព័ន្ធ សម្រាប់រាយការណ៍ពេលមានករណីគ្រោះថ្នាក់ការងារ ឬ ជួបបញ្ហាមិនប្រក្រតីណាមួយ ដើម្បីមកទទួលទៅតាមមន្ទីរពេទ្យចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ៕



# កិច្ចប្រជុំពិគ្រោះយោបល់ជាមួយមូលដ្ឋានសុខាភិបាលថ្នាក់ជាតិ អំពីការកំណត់តម្លៃឱសថក្រៅពីបញ្ជីឱសថសារវន្ត

**ឯកឧត្តម ស៊ុំ សោភ័ណ** នាយករងបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួង-ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈបានបើកកិច្ចប្រជុំពិគ្រោះយោបល់ជាមួយនឹងតំណាងថ្នាក់ដឹកនាំមូលដ្ឋានសុខាភិបាលថ្នាក់ជាតិ ចំនួន ៥ នៅក្នុង រាជធានីភ្នំពេញ។



ឯកឧត្តម ស៊ុំ សោភ័ណ នាយករងបេឡាជាតិរបបសន្តិសុខសង្គម អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំ

កិច្ចប្រជុំបានរៀបចំឡើងកាល ថ្ងៃព្រហស្បតិ៍ ៧កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១៨ នៅសាលប្រជុំ ប.ស.សដោយមានភាគីចូលរួមចំនួន៤០នាក់ ។ឯកឧត្តមបានបញ្ជាក់ថាកិច្ចប្រជុំនេះផ្តោត សំខាន់ទៅលើការ កំណត់តម្លៃឱសថ ក្រៅពីបញ្ជីឱសថសារវន្តសម្រាប់ព្យាបាលជំងឺលើសឈាមព្យាបាលជំងឺទឹកនោមផ្អែម និង សារធាតុគីមីសម្រាប់ព្យាបាលជំងឺមហារីក ជូនដល់សមាជិក ប.ស.ស ។

កិច្ចប្រជុំក៏បានពិគ្រោះយោបល់គ្នា ដោយជម្រុញឱ្យ មូលដ្ឋានសុខាភិបាលទាំង ថ្នាក់ជាតិ និង ឯកជនទាំងអស់ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស គប្បីយកចិត្ត ទុកដាក់ បន្ថែមទៀតទាក់ទងទៅ និងការមកទទួលសេវា ពិនិត្យព្យាបាល ជំងឺរបស់សមាជិក ប.ស.ស ប្រកបដោយ ប្រសិទ្ធភាព និង ទាន់ពេលវេលា។

**ឯកឧត្តម** បានបញ្ជាក់បន្ថែមថា កម្មករនិយោជិតមួយចំនួន នៅមិនទាន់យល់ដឹងពីនីតិវិធីក្នុងការទៅទទួលសេវាពិនិត្យ និងព្យាបាលដោយឥតគិតថ្លៃពីមន្ទីរពេទ្យដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស នៅឡើយ។ ដូច្នេះដើម្បីឱ្យមានភាពកាន់តែល្អប្រសើរឡើង សូមឱ្យមានការចូលរួមដោយយកចិត្តទុកដាក់បន្ថែមទៀតពីខាងមន្ទីរពេទ្យ។ ស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារបច្ចុប្បន្ន បេឡាជាតិរបបសន្តិសុខសង្គម បានចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋាន-សុខាភិបាលសាធារណៈ និង មន្ទីរពេទ្យឯកជន មានចំនួន ១ ៣២៥ មន្ទីរពេទ្យ។ នេះគឺជាការឆ្លើយតប ស្របតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលតម្រូវឱ្យកម្មករនិយោជិតទាំងក្នុង និង ក្រៅប្រព័ន្ធទាំងអស់ ទទួលបានសេវាគាំពារសង្គម៕



បទបង្ហាញអំពីបញ្ហាប្រឈម



# អ្នកព្រះឥសិរម្យ ឆាសាអ៊ូ ហៅទុំយ

## បណ្ដាំក្រមង៉ុយ

ពាក្យចាស់លោកថា ធ្វើស្រែចម្ការ ស្ដាប់មហាសង្ក្រាន្ត

ធ្វើម្ដងខុសខាត ធ្វើម្ដងទៀតបាន ធ្វើតាមប្រមាណ

ប្រមើលទឹកភ្លៀង។

រកប្ដីប្រពន្ធ ឱ្យគយឱ្យគន់ រើសរករូបរាង

ពូជថ្លៃល្មមយក ពូជថោកល្មមវាង រូបល្អឬកល្អៀង

នាងកុំប្រសព្វ។

ជាតិស្រីនិងប្រុស បើបានជាខុស ខុសទាល់តែចាស់ងាប់

បើបានរូបល្អ កម្រមានភ័ព្វ មានខុសមិនគាប់

ដូរស្រែចម្ការ។



# ខ្វះជាតិស្ករក្នុងឈាម គួរធ្វើដូចម្ដេចទៅ?

អាការៈខ្វះជាតិស្ករក្នុងឈាម មិនសូវកើតមានជាញឹកញាប់ទេ ប៉ុន្តែវាមានអត្រាគ្រោះថ្នាក់ដូចគ្នា ព្រោះវាអាចនាំឱ្យខូចខួរក្បាលបាន។ ករណីខ្លះ ទោះបីជាអ្នកជំងឺទឹកនោមផ្អែមក៏ដោយ ក៏អាចមានកម្រិតជាតិស្ករក្នុងឈាម ធ្លាក់ចុះក្រោមធម្មតាដែរ ក្រោយពីចាក់ថ្នាំអាំងស៊ុយលីន ឬលេបថ្នាំជំងឺទឹកនោមផ្អែមរួច។ បើសិនជាកម្រិតជាតិស្ករក្នុងឈាម នៅក្រោម ៨០ mg/dl មានន័យថា ជាបញ្ហាខ្វះជាតិស្ករក្នុងឈាម ហើយអាចសម្គាល់ដឹង តាមរយៈការបែកញើស និងសម្លប់។ បើសិនជាអ្នកធ្លាប់មាន អាការៈខ្វះជាតិស្ករក្នុងឈាម ខាងក្រោមនេះ គឺជាអ្វីដែលអ្នកត្រូវតែធ្វើ។

## ពិនិត្យជាតិស្ករក្នុងឈាម

បើសិនជាមនុស្សម្នាក់ទៅជាសន្លប់ ឬមានអាការៈខ្វះជាតិស្ករក្នុងឈាម ចូរព្យាយាមពិនិត្យជាតិស្កររបស់ពួកគេទៅ។ បើសិនជាលទ្ធផលឃើញចាប់ពី ៨០ mg/dl ចុះក្រោមនោះ ចូរឱ្យគេគេងលើផ្ទៃរាបស្មើ។ ចូរឱ្យអ្នកជំងឺបិទភ្នែក និងដកដង្ហើមធម្មតាពីរបីវិនាទី រហូតដល់គាត់មានអារម្មណ៍ធម្មតាវិញ។

## ញ៉ាំស្ករ

ចូរញ៉ាំរបស់ផ្អែមៗគ្រប់ប្រភេទ ឬភេសជ្ជៈផ្អែមៗណាមួយ ដើម្បីបង្កើនកម្រិតជាតិស្ករក្នុងឈាមឡើងវិញ។ ចូរឱ្យអ្នកជំងឺទំពារស្ករផ្អែម ឬស្ករកូឡា ព្រោះវាមានអត្រានៃការបឺតស្រូបជាតិស្ករក្នុងឈាមបានលឿន និង បង្កើនជាតិស្ករក្នុងឈាមវិញ ក្នុងរយៈពេលតែពីរបីនាទីប៉ុណ្ណោះ។ បើសិនអ្នកជំងឺមិនអាចទំពារបាន ចូរឱ្យគេញ៉ាំទឹកសូលុយស្យុងស្ករ ទឹកផ្លែឈើ ឬទឹកសូកូឡាមួយកែវទៅ។

## ពិគ្រោះជាមួយគ្រូពេទ្យ

មិនត្រូវរង់ចាំ ដល់ជាតិស្ករក្នុងឈាមធ្លាក់ចុះដល់ ៦០ mg/dl ឬទាបជាងនេះឡើយ។ កាលណាអ្នកជំងឺដឹងខ្លួនហើយ ប្រញាប់នាំគេទៅជួបគ្រូពេទ្យ ដើម្បីព្យាបាលភ្លាម។ ចំពោះអ្នកជំងឺទឹកនោមផ្អែម បើសិនជាជាតិស្ករក្នុងឈាមធ្លាក់ចុះធ្ងន់ធ្ងរ ឬអ្នកជំងឺនៅតែមិនដឹងខ្លួនទៀត ចូរនាំគេទៅកាន់មន្ទីរពេទ្យ ដែលជិតបំផុត និងចាក់អាំងស៊ុយលីនដល់គេទៅ។ មិនត្រូវទៅឱ្យគ្រូពេទ្យណាពិនិត្យ ដែលមានបន្ទប់ពិគ្រោះជំងឺ ឬគ្លីនិកឆ្ងាយៗឡើយ ព្រោះការពន្យារពេលព្យាបាល អាចបណ្តាលឱ្យជាតិស្ករថយចុះកាន់តែខ្លាំង និងខូចខាតដល់ខួរក្បាលកាន់តែខ្លាំង ព្រមទាំងមានផលវិបាកផ្សេងៗធ្ងន់ធ្ងរទៀត៕

# បេឡាជាតិរបបសន្តិសុខសង្គម
# National Social Security Fund



លេខទំនាក់ទំនងទីស្នាក់ការកណ្តាល

០២៣ ៩៩៨ ៤១៩ / ០២៣ ៩៩៨ ៤១៨
០២៣ ៨៨២ ៦២៣ / ០២៣ ៩៩៨ ៤១៧
០២៣ ៨៨១ ១៧៦ / ០២៣ ៧២២ ៣០៨
០២៣ ៧២២ ៣០៧ / ០២៣ ៧២២ ៣៧៨
០២៣ ៧២២ ៣៧៩ / ០២៣ ៧២២ ៣៩០
០២៣ ៨៨១ ១៣៩ / ០២៣ ៨៨២ ៤៣៤

## ទំនាក់ទំនងតាមរយៈ


*អាសយដ្ឋាន:* អាគារលេខ៣ មហាវិថីសហព័ន្ធរុស្សី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
*ទូរស័ព្ទ:* ០២៣ ៨៨ ២៤ ៣៤ | ៩៩ ៨៤ ១៧ | ៩៩ ៨៤ ១៨ | ៩៩ ៨៨ ១៩
*ទូរសារ:* ០២៣ ៨៨ ២៦ ២៣
*គេហទំព័រ:* www.nssf.gov.kh *អ៊ីម៉ែល:* info@nssf.gov.kh
*ហ្វេសបុក:* *បេឡាជាតិរបបសន្តិសុខសង្គម - ប.ស.ស*